# សុន្ទរកថា

## របស់ ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន

## ថ្លែងក្នុងឱកាសសន្និបាតបូកសរុបការងារព័ត៌មាន និងសោតទស្សន៍ ឆ្នាំ ២០០៩

## និង ទិសដៅការកិច្ចឆ្នាំ ២០១០

- **ឯកឧត្តម លោកជំទាវ**
- **ភ្ញៀវកិត្តិយស សមាជិក-សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី**

ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងឧត្តុង្គឧត្តមបំផុត ក្នុងនាមថ្នាក់ដឹកនាំនៃក្រសួងព័ត៌មានទាំងអស់ សូមសំដែងនូវក្តីសោមនស្សរីករាយ និងសូមស្វាគមន៍យ៉ាងកក់ក្តៅក្រៃលែង ចំពោះវត្តមានដ៏ច្រើនកុះករ របស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ដែលបានអញ្ជើញចូលរួមសន្និបាតបូកសរុបការងារប្រចាំ ឆ្នាំរបស់ក្រសួងព័ត៌មាន ញ៉ាំងសន្និបាតនេះ ឱ្យកាន់តែមានអត្ថន័យជ្រាលជ្រៅ និងឆ្លុះបញ្ចាំងឱ្យឃើញពីស្មារតីយក ចិត្តទុកដាក់ទទួលខុសត្រូវខ្ពស់លើការងារព័ត៌មាន និងសោតទស្សន៍ ព្រមទាំងសំដែងឱ្យឃើញនូវស្មារតីសហការ ឯកភាព មិត្តភាព សាមគ្គីភាពយ៉ាងស្អិតល្មួតបំផុត ។

រយៈពេលមួយឆ្នាំកន្លងទៅ គ្រប់ផ្នែកគ្រប់ជំនាញទាំងអស់ បានបំពេញការងារយ៉ាងមមាញឹកពោរពេញទៅដោយការទទួលខុសត្រូវ និងការច្នៃប្រឌិតតាមតួនាទី និងភារកិច្ចរៀងខ្លួន ដោយឆ្លងកាត់ការលំបាក ការងាយស្រួលជាច្រើន តែជាលទ្ធផលយើងបានធ្វើឱ្យវិស័យព័ត៌មាន និងសោតទស្សន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានការវិវត្តរីកចម្រើនជាលំដាប់ រួមចំណែកក្នុងការពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ធានាបាននូវសិទ្ធិសេរីភាព សារព័ត៌មាន ហើយជាពិសេសទៅទៀតនោះ យើងបានបំពេញតួនាទីដ៏សំខាន់របស់យើងគឺ : ផ្តល់ព័ត៌មាន ផ្តល់ការអប់រំ និងផ្តល់ការកម្សាន្តសប្បាយ ជូនប្រជាពលរដ្ឋយើងនៅគ្រប់ទិសទី តាមទិសស្លោករបស់យើងគឺ “ **ប្លែក លឿន ទុកចិត្តបាន នៅទីណា ពេលណាក៏បាន** ” ។ អ្នកសារព័ត៌មានយើងទាំងអស់ ទាំងនៅក្នុងក្របខ័ណ្ឌរដ្ឋ ក្រុមហ៊ុនឯកជន និងសង្គមស៊ីវិល សុទ្ធតែបានលះបង់គ្រប់បែបយ៉ាង ដើម្បីផ្តល់សេវាកម្មតាមប្រព័ន្ធផ្សព្វផ្សាយរបស់ខ្លួន ជូនប្រជាពលរដ្ឋ និងទទួលព័ត៌មានពីប្រជាពលរដ្ឋជូន ដល់រាជរដ្ឋាភិបាលវិញ ។

**អង្គសន្និបាតជាទីគោរព** !

ឆ្នាំ ២០០៩ កន្លងមកនេះ ក្រសួងព័ត៌មានបានបង្កើនការខិតខំរបស់ខ្លួនបំពេញតួនាទី និងភារកិច្ច ដែលរាជរដ្ឋាភិបាលប្រគល់ជូន ដោយធ្វើឱ្យមានការប្រែប្រួលរីកចម្រើនមួយកម្រិតទៀត លើការពង្រឹងពង្រីកគុណភាព និងវិសាលភាពនៃការផ្សព្វផ្សាយ ។ បណ្តាញផ្សព្វផ្សាយរបស់រដ្ឋយើងរួមមាន : វិទ្យុជាតិកម្ពុជា ( AM918 KHz FMជាតិ 96 MHz FMជាតិវត្តភ្នំ 105.75 MHz ) ទូរទស្សន៍ជាតិកម្ពុជា ទីភ្នាក់ងារសារព័ត៌មាន ទស្សនាវដ្តីកម្ពុជា (KAMBUJA) វិទ្យុ-ទូរទស្សន៍តាម ខេត្ត-រាជធានី រួមនឹងមន្ទីរព័ត៌មានទាំងអស់ បាននិងកំពុងបំពេញតួនាទីរបស់ខ្លួន យ៉ាងមមាញឹក និងផុលផុស បង្កើតបានជាបណ្តាញប្រទាក់ក្រឡាគ្នា ធ្វើយ៉ាងណាឱ្យវិសាលភាព នៃការផ្សព្វផ្សាយគ្របដណ្តប់បានពេញទូទាំងប្រទេស ។ គោលដៅរបស់យើង គឺចង់ឱ្យប្រជាពលរដ្ឋទូទាំងប្រទេស ទោះជានៅតំបន់ដាច់ស្រយាល ចុងកាត់មាត់ញក

ណាក៏ដោយ ក៏ទទួលបានដោយសមធម៌ នូវព័ត៌មានផ្លូវការ ជាព័ត៌មានពិតត្រឹមត្រូវ ទទួលបានចំណេះដឹងនិងការអប់រំ ប្រកបដោយគុណធម៌មានខ្នាតគំរូច្បាស់លាស់ និងទទួលបានការកម្សាន្តសប្បាយដ៏ស្អាតស្អំ ប្រកបដោយសីលធម៌ ។

**គណៈអធិបតីជាទីគោរព** !

**សមាជិក-សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី** !

ដោយអនុវត្តតាមយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលដំណាក់កាលទី២ ដែលបានគូសបញ្ជាក់ថា " **ពង្រីកវិសាលភាព គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិគ្របដណ្តប់បានទំលំទូលាយ ទាំងក្នុងប្រទេស ក្នុងតំបន់ និងទ្វីបនានា** " ផងនោះ ក្រសួងព័ត៌មាន បានយកចិត្តទុកដាក់ពង្រឹងពង្រីក បណ្តាញផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ នៅថ្នាក់ជាតិ យើងបានដាក់ឱ្យដំណើរការ វិទ្យុជាតិវត្តភ្នំ FM 105.75 MHz ដោយបានផ្សាយស្របគ្នាជាមួយ AM 918 KHz បានសេចក្តីថា ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញអាចបើកស្តាប់វិទ្យុ AM918 KHz ក៏បាននិងបើកស្តាប់ FM 105.75 MHz ក៏បាន។ ទូរទស្សន៍ជាតិកម្ពុជា បានដាក់ឱ្យដំណើការជាផ្លូវការនូវប្រព័ន្ធផ្សាយត្រង់ទៅដល់គេហដ្ឋាន (DTH) និងបានផ្សាយតាមប្រព័ន្ធ T-DMB មួយទៀត ដែលប្រជាពលរដ្ឋអាច ទស្សនាទូរទស្សន៍ជាតិកម្ពុជា និងទូរទស្សន៍បាយ័ន តាមរថយន្តក៏បាន ។ ក្រៅពីប្រព័ន្ធនេះ ទូរទស្សន៍មួយចំនួន ត្រូវបានផ្សាយតាមផ្កាយរណបទៅកាន់ពិភពលោក ហើយទូរទស្សន៍ទាំងអស់ សុទ្ធតែត្រូវផ្សាយតាមប្រព័ន្ធ Internet ថែមទៀត ដែលធ្វើឱ្យប្រជាជនកម្ពុជាយើងនៅឯបរទេសអាច ទទួលព័ត៌មានគ្រប់ប្រភេទពីមាតុភូមិរបស់ខ្លួន ។ ស្ថានីយវិទ្យុតាម ខេត្ត-រាជធានី ដែលមានស្រាប់ ត្រូវបានកែលំអ ទាំង ប្រព័ន្ធការងារ និងប្រព័ន្ធបច្ចេកទេស ហើយ ខេត្ត-រាជធានី មួយចំនួនទៀត បានបំពាក់ស្ថានីយវិទ្យុថ្មី។ រហូតមកដល់ពេល នេះ ខេត្តចំនួន ១២ មានស្ថានីយវិទ្យុរបស់ខ្លួន។ ទន្ទឹមនិងនេះ យើងបានយកចិត្តទុកដាក់កែលំអ ជាបណ្តើរៗ នូវស្ថានីយទូរទស្សន៍ របស់ ខេត្ត-រាជធានី ទាំង ៧ ដែលមានស្រាប់ ។

នៅថ្នាក់កណ្តាល និងថ្នាក់រាជធានី-ខេត្ត យើងបានបំពាក់មធ្យោបាយសម្រាប់បម្រើការងារចាំបាច់ជាបណ្តើរៗ ដូចជា កុំព្យូទ័រ ម៉ាស៊ីនហ្វាក់ ម៉ាស៊ីនថតរូប....ទោះបីជាមិនទាន់ឆ្លើយតបបានតាមសំណូមពរ តែយើងអាច ដំណើរការទៅមុខបាន ជាបណ្តើរៗ។ ចំពោះកន្លែងធ្វើការ ទាំងនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន យើងបានរៀបចំជួសជុលកែលំអ និងសាងសង់ថ្មី ដើម្បី បង្កលក្ខណៈងាយស្រួលដល់មន្ត្រីរាជការ យើងបំពេញការងារ បានសមរម្យ និងប្រកបដោយផាសុកភាព ។

ដោយឡែក ចំពោះបណ្តាញផ្សព្វផ្សាយ របស់ក្រុមហ៊ុនឯកជន និងរបស់អង្គការមិនមែនរដ្ឋាភិបាល ថ្វីត្បិត តែអង្គភាពមួយចំនួនតូច នៅមានចំណុចអវិជ្ជមានក្តី ប៉ុន្តែជាទូទៅបានដំណើរការយ៉ាងល្អប្រសើរ ក្នុងការផ្តល់ព័ត៌មាន ផ្តល់ការអបរំ និងចំណេះដឹង និងផ្តល់ការកម្សាន្តសប្បាយជូនប្រជាពលរដ្ឋយើងផុលផុស និងប្រកបដោយលក្ខណៈប្រកួតប្រជែង ដោយ ស្មើភាព ក្នុងការផ្តល់សេវាផ្សព្វផ្សាយនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឈរលើស្មារតីគោរពច្បាប់ស្តីពីរបបសារព័ត៌មាន ក្រមសីលធម៌ វិជ្ជាជីវៈសារព័ត៌មាន ។ ក្រសួងព័ត៌មាន តែងតែបានកោតសរសើរ និងលើកទឹកចិត្ត ដល់អង្គភាពទាំងនោះ ដែលប្រកាន់ខ្ជាប់ នូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន តែទន្ទឹមនឹងនោះ ក្រសួងព័ត៌មានតែងតែណែនាំក្រើនរំលឹកដល់អង្គភាពមួយចំនួន ដែលផ្សព្វផ្សាយរំលោភលើរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីរបប

សារព័ត៌មាន និងច្បាប់នានា ជាពិសេសការផ្សព្វផ្សាយប្រាសចាកសីលធម៌ បំពានលើ វប្បធម៌ប្រពៃណីជាតិ ដ៏ល្អផូរផង់របស់យើង ។

ឆ្លៀតក្នុងឱកាសនេះ តាងនាមក្រសួងព័ត៌មាន ខ្ញុំសូមថ្លែងនូវការអបអរសាទរ និងអំណរគុណ យ៉ាងជ្រាលជ្រៅ ចំពោះបណ្តាញផ្សព្វផ្សាយគ្រប់ប្រភេទ ទាំងជាតិ-អន្តរជាតិ ដែលបានរួមចំណែកយ៉ាងសំខាន់ ក្នុងការបម្រើ ប្រជាពលរដ្ឋ ក៏ដូចជា ជួយដល់រាជរដ្ឋាភិបាលកម្ពុជា ។

**អង្គសន្និបាត ជាទីគោរព** !

ប្រទេសជាតិយើង កំពុងតែវិវត្តរីកចម្រើនទៅមុខ ក្នុងមុមសន្តិភាព និងស្ថិរភាពនយោបាយ សភាពការណ៍ទាំងឡាយក៏វិវត្តទៅតាមស្ថានភាពសង្គម និងសេដ្ឋកិច្ចនេះផងដែរ ហើយហេតុការណ៍ និងព្រឹត្តិការណ៍ជាច្រើន នឹងកើតមានឡើង ដូច្នេះយើងទាំងអស់គ្នាជាអ្នកសារព័ត៌មាន ក៏មានតួនាទីភារកិច្ច រួមចំណែកក្នុងការការពារសន្តិភាព និងស្ថិរភាពនយោបាយ ដែលជាគន្លឹះក្នុងការអភិវឌ្ឍប្រទេសជាតិ ។ ភារកិច្ចរបស់យើង គឺថ្លៃថ្លា និងពោរពេញ ទៅដោយមោទនភាព ។ ដូច្នេះ ខ្ញុំសូមឱ្យ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់បន្ត នូវស្មារតីទទួលខុសត្រូវ យកអស់កំលាំងកាយចិត្តប្រាជ្ញា បង្កើត ការច្នៃប្រឌិតបន្ថែមទៀត ដើម្បីបំពេញភារកិច្ចតាម មុខសញ្ញារៀងៗខ្លួន ឱ្យទទួលបានជោគជ័យលើសឆ្នាំកន្លងទៅថែមទៀត ។

ក្នុងឱកាសសន្និតបាតនាពេលនេះ ទាំងអស់គ្នា ត្រូវខិតខំលើកយោបល់ និងពិភាក្សាគ្នា បង្ហាញនូវចំណុចល្អៗ និងបទពិសោធន៍ល្អៗ ពិនិត្យពិចារណា កែលំអនូវចំណុចខ្វះខាត ចំណុចសេសសល់ និងបញ្ហាប្រឈម ទាំងឡាយដើម្បីលើកទិសដៅការងារឱ្យចំគោល ដៅ ដោះស្រាយបញ្ហាឱ្យចំចំណុចរសើប ហើយយើងនៅតែចាត់ទុក ទិសស្លោក “ **ប្លែក លឿន ទុកចិត្តបាន នៅទីណា ពេលណាក៏បាន** ” ជាផែនទីបង្ហាញផ្លូវ ដ៏មានប្រសិទ្ធភាព សម្រាប់យើងទាំងអស់គ្នា ។

ក្នុងឱកាសដ៏មហោឡារឹកនេះ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងព័ត៌មានទាំងអស់ ខ្ញុំសូមសំដែងនូវការដឹងគុណ និងសូមថ្វាយព្រះពរ ព្រះករុណា **ព្រះបាទសម្តេច ព្រះបរមនាថ សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចព្រះមហាវីរក្សត្រ នរោត្តម សីហនុ** និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ដែលបានគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ ដល់ប្រជារាស្ត្រយើង ។ សូមជូនពរ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា **សម្តេច អគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំ ប្រទេសជាតិឱ្យមានការរីកចម្រើន សំបូររុងរឿងលើគ្រប់វិស័យ ...។

ខ្ញុំសូមប្រកាសបើកសន្និបាត ក្រសួងព័ត៌មាន និងសូមប្រសិទ្ធិពរជូនអង្គសន្និបាត ឱ្យទទួលបានជោគជ័យ ។

**សូមអរគុណ** !